ទីស្នាក់ការ : អគារលេខ៨៥-៨៨ មហាវិថីគីម អ៊ីលស៊ុង (២៨៩)
សង្កាត់បឹងកក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ
ទូរសព្ទ័លេខ : (855) 85 500 555
E-mail: hda.cambodia@gmail.com   Web: www.hdacambodia.com

# សមាគមអ្នកអភិវឌ្ឍន៍លំនៅឋានកម្ពុជា



# មាតិកា


**១.មតិស្វាគមន៍**

១.២.រចនាសម្ព័ន្ធថ្នាក់គ្រប់គ្រង ........ 7

១.២.ឈ្មោះសមាជិក-សមាជិកា ........ 12

**២.វឌ្ឍនភាពរបស់វិស័យសំណង់ក្នុងព្រះរាជាណាចក្រកម្ពុជា**

២.១.សំណង់សម័យអង្គរ ........ 18

២.២.សំណង់សម័យបារាំង ........ 20

២.៣.សំណង់សម័យខ្មែរក្រហម ........ 22

២.៤.សំណង់បច្ចុប្បន្ន ........ 26

**៣. ផែនការអភិវឌ្ឍន៍រាជធានីភ្នំពេញរបស់រាជរដ្ឋាភិបាល**

**៤.ភាពជាដៃគូរវាងវិស័យឯកជន និងរាជរដ្ឋាភិបាលក្នុងការជម្រុញ វិស័យអចលនទ្រព្យ និងសំណង់**

៤.១.បុរី វិមានភ្នំពេញ ........ 40

៤.២.បុរី ប៉េង ហួត គ្រុប ........ 44

៤.៣.បុរី វីឡាទួលសង្កែ ........ 48

៤.៤.សំណង់ល្អ ថ្មីពេញចិត្ត ........ 50

៤.៥.បុរី មង្គលភ្នំពេញ ........ 52

៤.៦.បុរី អង្គរភ្នំពេញ ........ 56

៤.៧.បុរី ថៃឈុនគ្រី ........ 58

៤.៨.បុរី តាំង លីម ........ 60

៤.៩.បុរី ជីបម៉ុងលែន ........ 62

៤.១០.បុរី ឌឹមេគង្គរ៉ូយ៉ាល់ ........ 64

៤.១១.បុរី វ៉ារីណា ........ 68

៤.១២.បុរី ហុង ឡាយ ........ 70

៤.១៣.បុរី ឡាយ គង់ ........ 72

៤.១៤.បុរី លីម ឈាងហាក់ ........ 74

៤.១៥.បុរី លឹម ឈាងហោ ចំការដូង ........ 76

៤.១៦.សំណង់ផ្ទះល្វែងសូឈីវ ព្រំខយ ........ 78

៤.១៧.បុរី ធូ លន ........ 80

៤.១៨.បុរី ពិភពថ្មី ........ 82

៤.១៩.បុរី អ័រគីដេវិឡា ........ 84

៤.២០.ទីក្រុងរណប ហ្គ្រេន ភ្នំពេញ ........ 86

៤.២១.បុរី ភ្នំពេញថ្មី ........ 90

៤.២២. អាល់ហ្វា ប្រធីធី ខនស្ត្រាក់សិន ........ 92

៤.២៣. ខេមបូឌាន នេជ្រល ឡាក់ឃី រៀលអ៊ីស្ទេត ឌីវេឡុបមេន ខូអិលធីឌី ........ 94

៤.២៤.បុរី រំចេក ........ 96

៤.២៥.បុរី ជារី ........ 98

៤.២៦.បុរី ជ័យឧត្តម ........ 100

៤.២៧.បុរី គ្រីស្គាល់ ........ 102

៤.២៨.ខុនដូ ឌឹ រីវើ ........ 104

៤.២៩.បុរី ហេង មានជ័យ ........ 106

៤.៣០.បុរី ហាយធិច ........ 108

៤.៣១.ខុនដូ វិមានកែវចរណៃ ........ 110

៤.៣២.បុរី ហាយលែន ស៊ីធី ........ 112

៤.៣៣.បុរី ផុនស៊ុយ ........ 114

៤.៣៤.បុរី ពេជ្រ ........ 116

៤.៣៥.បុរី រិទ្ធិ ........ 118

៤.៣៦.បុរី សម្បត្តិមានហេង ........ 120

៤.៣៧.បុរី សម្បត្តិមាស ........ 122

៤.៣៨.បុរី ឌឹ ផ្លូរ៉ា ........ 124

៤.៣៩.ខុនដូ ដេ ខេសសល រ៉ូយ៉ាល់ ........ 126

៤.៤០.កម្ពុ បុរី ........ 128

៤.៤១. ណត ផាក ខុនដូ ........ 130

៤.៤២. លំនៅឋាន អិល កម្ពុជាភ្នំពេញ ........ 132

៤.៤៣.បុរី រីវើថោន ........ 134

៤.៤៤.បុរី ចតុមុខ ស៊ីធី ........ 136

៤.៤៥. ឌឹ ប្រ៊ីដ ........ 138

៤.៤៦.ឌឹ ព្រីមមើ អង្គរ ផាលេស ........ 140

សមាគមអ្នកអភិវឌ្ឍន៍លំនៅឋានកម្ពុជា

Housing Development Association of Cambodia



រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ: ៩៨៥៧ ប្រក

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ប្រកាស**
**ស្តីពី**
**ការចុះឈ្មោះក្នុងបញ្ជីសមាគម**

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ន ស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨១៥/០១០ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងលិខិតលេខ ០០១/ HDAC ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៥ របស់ឧកញ៉ា **លី ហួរ** ប្រធានសមាគមអ្នកអភិវឌ្ឍន៍លំនៅឋានកម្ពុជា

**សម្រេច**

**ប្រការ ១** ..

ត្រូវបានចុះឈ្មោះ **សមាគមអ្នកអភិវឌ្ឍន៍លំនៅឋានកម្ពុជា** ក្នុងបញ្ជីសមាគមនៅក្រសួងមហាផ្ទៃ ដែលមានអាស័យដ្ឋាន នៃទីស្នាក់ការកណ្តាលតាំងនៅផ្ទះលេខ**២៤៣-២៤៤** ផ្លូវលេខ**៥៩៨** ភូមិ**ទួលគោក** សង្កាត់**ទួលសង្កែ** ខណ្ឌ**ឫស្សីកែវ** រាជធានីភ្នំពេញ។

**ប្រការ ២** ..

**សមាគមអ្នកអភិវឌ្ឍន៍លំនៅឋានកម្ពុជា** ត្រូវធ្វើសកម្មភាពស្របតាមច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល លិខិតបទដ្ឋានគតិយុត្តនានាជាធរមាន និងលក្ខន្តិកៈរបស់ខ្លួនដូចបានតម្កល់ទុកនៅក្រសួងមហាផ្ទៃ ដោយមិនមានការរើសអើង ការប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ឬសាសនាណាមួយឡើយ។

**ប្រការ ៣** ..

អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល អគ្គស្នងការ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកដ្ឋានពាក់ព័ន្ធនានា នៃក្រសួងមហាផ្ទៃ អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ ប្រធាននាយកដ្ឋានកិច្ចការសមាគម និងគណបក្សនយោបាយ និងសាមីសមាគមដូចមានឈ្មោះក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ តុលា ឆ្នាំ២០១៥

**ឧ. រដ្ឋមន្ត្រី**
**រដ្ឋលេខាធិការ**

ប៉ុល លឹម

**កន្លែងទទួល:**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ធនាគារជាតិ នៃកម្ពុជា
  (ដើម្បីជូនជ្រាប)
- ដូចប្រការ ៣ (ដើម្បីអនុវត្ត)
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ

# រចនាសម្ព័ន្ធថ្នាក់គ្រប់គ្រង
# សមាគមអ្នកអភិវឌ្ឍន៍លំនៅឋានកម្ពុជា



លោកឧកញ៉ា លី ហួរ
ប្រធាន



បណ្ឌិត តាន់ មុនីវណ្ណ
ទីប្រឹក្សា



អ្នកឧកញ៉ា
ហុង ពីវ
អនុប្រធាន



លោកឧកញ៉ា
ថៃ ជាហួត
អនុប្រធាន



លោកឧកញ៉ា
លាង ម៉េង
អនុប្រធាន



លោកឧកញ៉ា
ជាម យុនណាត
អនុប្រធាន



លោកឧកញ៉ា
តេង ហឿង
អនុប្រធាន



លោកជំទាវ
ខា ឡេង
អនុប្រធាន



លោកជំទាវឧកញ៉ា
កែវ ម៉ាលី
អនុប្រធាន



លោកឧកញ៉ា
លាង សាំង
អនុប្រធាន



លោកឧកញ៉ា
លី សេងឃាង
អនុប្រធាន



លោកឧកញ៉ា
តាំង គួង
អនុប្រធាន

# អគ្គលេខាធិការដ្ឋាន



លោក ហ៊ុយ វណ្ណា
អគ្គលេខាធិការ



ទីប្រឹក្សាច្បាប់
លោក ប៊ុ វណ្ណះ



ហេរញ្ញិក
លោក គឹម ធារិទ្ធ



លេខាធិការ
កញ្ញា ប៉ូ សុគន្ធា



ជំនួយការ ទីប្រឹក្សាច្បាប់
លោក លីម វ៉ាន់ដារ័ត្ន

# ក្រុមប្រឹក្សាភិបាលសមាគមអ្នកអភិវឌ្ឍន៍លំនៅឋានកម្ពុជា



**លោកឧកញ៉ា លី ហួរ**
**ប្រធានសមាគម**

លោកឧកញ៉ា លី ហួរ អគ្គនាយកក្រុមហ៊ុន លី ហួរ គ្រុប និងជាអនុប្រធានសភាពាណិជ្ជកម្មកម្ពុជា។ លោកឧកញ៉ា មានស្រុកកំណើតនៅខេត្តកំពង់ចាម។ នៅឆ្នាំ ១៩៨៦ លោកបានសម្រេចចិត្តបង្កើតអាជីវកម្មប្តូរប្រាក់ ដែលទទួលបានជោគជ័យយ៉ាងខ្លាំងក្នុងវិស័យហិរញ្ញវត្ថុ។ លើសពីនេះទៅទៀត លោកឧកញ៉ា បានពង្រីកអាជីវកម្មរបស់ខ្លួន តាមរយៈក្រុមហ៊ុន លី ហួរ គ្រុប ដែលបានវិនិយោគក្នុងវិស័យផ្សេងៗគ្នា ដូចជា អចលនទ្រព្យ និងសំណង់, ហិរញ្ញវត្ថុ និងកសិឧស្សាហកម្មផងដែរ។ លោកបានរួមចំណែកវិភាគទានយ៉ាងច្រើន សម្រាប់ជួយដល់វិស័យសេដ្ឋកិច្ចនៅក្នុងប្រទេស និងលើកកម្ពស់ វិស័យបណ្តុះបណ្តាលធនធានមនុស្សឲ្យប្រសើរឡើង ដែលធ្វើឲ្យលោកបានទទួលលិខិតសរសើរ ពានរង្វាន់ និងមេដាយជាច្រើន។



**អ្នកឧកញ៉ា ហុង ពីវ**
**អនុប្រធាន**

អ្នកឧកញ៉ា ហុង ពីវ អគ្គនាយក គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ពិភពថ្មី និងបុរីពិភពថ្មី។ លោកមានស្រុកកំណើតនៅរាជធានីភ្នំពេញ។ បុរី ពិភពថ្មី គឺជាក្រុមហ៊ុនវិនិយោគក្នុងស្រុកដែលផ្តត់ផ្គង់លំនៅឋាន ដល់អតិថិជនគ្រប់លំដាប់ថ្នាក់នៅព្រះរាជាណាចក្រកម្ពុជា សំណង់អគារលំនៅឋានជាលក្ខណៈបុរីដែលមានជាច្រើនទីតាំងនៅជុំវិញរាជធានីភ្នំពេញ។



**លោកឧកញ៉ា លាង ម៉េង**
**អនុប្រធាន**

លោកឧកញ៉ា លាង ម៉េង ជាប្រធានក្រុមប្រឹក្សាភិបាល ក្រុមហ៊ុន ជីប ម៉ុង គ្រុប ដែលជាក្រុមហ៊ុនវិនិយោគក្នុងស្រុក ត្រូវបានបង្កើតតាំងពីឆ្នាំ ១៩៨២។ បច្ចុប្បន្ន ក្រុមហ៊ុន ជីប ម៉ុង គ្រុប ជាក្រុមហ៊ុនឈានមុខគេ ក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងការនាំចូល និងចែកចាយនូវសម្ភារៈសំណង់ និងសម្ភារៈបន្ទប់ទឹកគ្រប់ប្រភេទ។ លើសពីនេះទៀត ក្រុមហ៊ុន ជីប ម៉ុង លែន ដែលជាម្ចាស់គម្រោង The Park Land Sen Sok ក៏ជាបុត្រសម្ព័ន្ធរបស់ក្រុមហ៊ុន ជីប ម៉ុង គ្រុបផងដែរ។



**លោកឧកញ៉ា ថៃ ជាហួត**
**អនុប្រធាន**

លោកឧកញ៉ា ថៃ ជាហួត ប្រធានក្រុមប្រឹក្សាភិបាល ក្រុមហ៊ុន បុរី ប៉េង ហួត ។ បុរី ប៉េង ហួត គ្រុបបាន ចាប់ផ្តើមដំណើរការតាំងពីឆ្នាំ២០០៥ ក្នុងគោលដៅពង្រីកសក្តានុពលទីផ្សារ ប្រកបដោយការទទួលខុសត្រូវខ្ពស់សម្រាប់ជាទំនុកចិត្តដល់អតិថិជនក្នុងការ ស្វែងរកលំនៅឋានសាកសមនឹងកម្រិតជីវិភាពរបស់ខ្លួន។ ភាពរីកចម្រើននេះ ហើយធ្វើឲ្យបុរី ប៉េង ហួត បានឈ្នះពានរង្វាន់ចំនួន៥ ក្នុងការអភិវឌ្ឍន៍វិស័យអចលនទ្រព្យ និងសំណង់ក្នុងព្រះរាជាណាចក្រកម្ពុជា។



**លោកឧកញ៉ា ជាម យុនណាត**
**អនុប្រធាន** ទទួលបន្ទុកគណៈកម្មាធិការទំនាក់ទំនង ជាតិ និងអន្តរជាតិ

លោកឧកញ៉ា ជាម យុនណាត ជាក្រុមប្រឹក្សាភិបាលនៃ បុរីមេគង្គរ៉ូយ៉ាល់ និង បុរីអ័រគីដេវីឡា ។ លោកឧកញ៉ា មានស្រុកកំណើតនៅស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល។ នៅឆ្នាំ១៩៩៧ លោកឧកញ៉ាបានក្លាយជាអគ្គនាយកក្រុមហ៊ុន នាំចេញ នាំចូល ខេ អិន អិន ខេមបូឌា។



**លោកឧកញ៉ា តេង ហឿង**

**អនុប្រធាន** ទទួលបន្ទុកគណៈកម្មាធិការ ហិរញ្ញវត្ថុ

លោកឧកញ៉ា តេង ហឿង មានស្រុកកំណើតនៅខេត្តកំពត។ លោកឧកញ៉ា ជាអគ្គនាយករងរបស់ ក្រុមហ៊ុនដឹកជញ្ជូន តេង ឡាយ គ្រុប។ នៅឆ្នាំ២០១៥ លោកឧកញ៉ា បានក្លាយជាអនុប្រធានគម្រោង របស់បុរី អ័រគីដេវីឡា ជាក្រុមហ៊ុនវិនិយោគផ្នែកសំណង់អចលនទ្រព្យដ៏ធំ ដែលកំពុងប្រកួតប្រជែងក្នុងទីផ្សារក្នុងរាជធានីភ្នំពេញ។



**លោកជំទាវ ខា ឡេង**

**អនុប្រធាន** ទទួលបន្ទុកគណៈកម្មាធិការ អប់រំ បណ្តុះបណ្តាល និងស្រាវជ្រាវ

លោកជំទាវ ខា ឡេង ជាអគ្គនាយិការង អាល់ហ្វា ប្រធីធី ខនស្ត្រាក់សិន។ លោកជំទាវ បានបញ្ចប់ថ្នាក់អនុបណ្ឌិត និង កំពុងសិក្សាថ្នាក់បណ្ឌិត ផ្នែកច្បាប់។ ក្រុមហ៊ុន អាល់ហ្វា ប្រធីធី ខនស្ត្រាក់សិន ជាក្រុមហ៊ុនមានបទពិសោធន៍ជាច្រើនឆ្នាំ ខាងផ្នែកអចលនទ្រព្យ និងសំណង់ផងដែរ ដែលក្រុមហ៊ុនបានកំពុងវិនិយោគ គម្រោងធំៗជាច្រើនដូចជា គម្រោង The Gate Way ជាដើម។



**លោកជំទាវឧកញ៉ា កែវ ម៉ាលី**

**អនុប្រធាន**

លោកជំទាវឧកញ៉ា កែវ ម៉ាលី ជាអគ្គនាយិកា ខុនដូ វិមានកែវចរណៃ។ លោកជំទាវឧកញ៉ា មានស្រុកកំណើតនៅ រាជធានីភ្នំពេញ។ សព្វថ្ងៃលោកជំទាវ គឺជាអនុប្រធានសភាពាណិជ្ជកម្មកម្ពុជា និង ប្រធាន ក្រុមហ៊ុន Crystal Rice (Kampuchea) Co., Ltd ដែលមានលទ្ធភាពកិនស្រូវបាន២០០តោនក្នុងមួយថ្ងៃ នៅកំពង់ផែខេត្តកំពត និងក្រុមហ៊ុន កែវ ម៉ាលី ។



**លោកឧកញ៉ា លី សេងឃាង**

**អនុប្រធាន**

លោកឧកញ៉ា លី សេងឃាង ជាប្រធានក្រុមហ៊ុន BS Land and Home ជាក្រុមហ៊ុនវិនិយោគផ្នែកសំណង់ផ្ទះល្វែង វិឡា និងខុនដូ បើគិតមកសព្វថ្ងៃ ក្រុមហ៊ុន BS Land and Home បាន វិនិយោគលើគម្រោង៣គឺ គម្រោង ចតុមុខ ស៊ីធីវីយូ ខុនដូ, គម្រោង ចតុមុខ ស៊ីធីទី១ និង គម្រោង ចតុមុខ ស៊ីធីទី២ ក្នុងតំបន់ស្វាយជ្រុំ ខេត្តកណ្តាល។



**លោកឧកញ៉ា តាំង គួង**

**អនុប្រធាន**

លោកឧកញ៉ា តាំង គួង អគ្គនាយក ក្រុមហ៊ុន TANG KUNG GROUP Co., Ltd. ។ លោកមានស្រុកកំណើតនៅខេត្តកំពង់ចាម។ នៅឆ្នាំ ១៩៩៧ លោកឧកញ៉ា ជាប្រធាន ក្រុមហ៊ុនបោះពុម្ព Digital Advertising ក្រុមហ៊ុនទទួលបានវិញ្ញាបនបត្រ ISO 9001 លើគុណភាពនិងសេវាបោះពុម្ពនៅឆ្នាំ ២០១២ ។ ពីឆ្នាំ ២០០៤-២០១៤ លោកបានពង្រីកអាជីវកម្មថែមទៀតតាមរយៈក្រុមហ៊ុន តាំង គួង គ្រុប ដែលបានវិនិយោគលើអចលនទ្រព្យ និងសំណង់ដូចជាគម្រោង Center City Takmao ។



**លោកឧកញ៉ា លាង សាំង**

**អនុប្រធាន**

លោកឧកញ៉ា លាង សាំង ជានាយកក្រុមហ៊ុន ហាយ ធិច និងជាអគ្គនាយក បុរី ហាយធិច។ ក្រុមហ៊ុន បុរី ហាយធិច បានវិនិយោគសំណង់លំនៅឋានជា វិឡាប្រណិត និងក្លិបហាត់ប្រាណជាដើម។ បើគិតមកដល់សព្វថ្ងៃ ក្រុមហ៊ុន អេសអិល ហាយធិច ខូអិលធីឌី មានគម្រោងបុរី ហាយ ធិច, បុរី ហាយ ធិច ២, បុរី ហាយ ធិច លុច្សសារី, អាគារពណ៌ស៦ជាន់ និងក្រុមហ៊ុនបុត្រសម្ព័ន្ធមួយចំនួនទៀត។

## អគ្គលេខាធិការដ្ឋាន



**បណ្ឌិត តាន់ មុនីវណ្ណ**

**ទីប្រឹក្សាបច្ចេកទេស**

លោក តាន់ មុនីវណ្ណ មានស្រុកកំណើតនៅ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម។ លោកបានបញ្ចប់ថ្នាក់ បណ្ឌិតច្បាប់ និង បណ្ឌិតគ្រប់គ្រងពាណិជ្ជកម្ម និង រដ្ឋបាល។ សព្វថ្ងៃ លោកគឺជា អនុប្រធានក្រុមហ៊ុន ម៉ុង ឫទ្ធី គ្រុប និងជាសមាជិក នៃសភាពាណិជ្ជកម្មកម្ពុជា។



**លោក ហ៊ុយ វណ្ណា**

**អគ្គលេខាធិការ**

លោក ហ៊ុយ វណ្ណា មានស្រុកកំណើតនៅខេត្តតាកែវ។ លោកបានបញ្ចប់ថ្នាក់ បរិញ្ញាបត្រផ្នែកច្បាប់។ មុននឹងចូលបម្រើការងារនៅសមាគមអ្នកអភិវឌ្ឍន៍លំនៅឋានកម្ពុជា លោកបានបម្រើការងារនៅធនាគារអេស៊ីលីដា ភីអិលស៊ី ជាង៨ឆ្នាំ តួនាទីប្រធានសវនករផ្ទៃក្នុង បន្ទាប់មកបម្រើការងារនៅបុរីវិមានភ្នំពេញ ជាង២ឆ្នាំ តួនាទីជាប្រធាននាយកដ្ឋានទំនាក់ទំនងកិច្ចការសាធារណៈ និងរដ្ឋបាល និងបម្រើការងារនៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ លី ហួរ ភីអិលស៊ី តួនាទីជានាយករងនាយកដ្ឋានគាំទ្រអាជីវកម្ម។



**លោក ប៊ិ វណ្ណៈ**

**ទីប្រឹក្សាផ្នែកច្បាប់**

លោក ប៊ិ វណ្ណៈ មានស្រុកកំណើតនៅស្រុកកោះសូទិន ខេត្តកំពង់ចាម។ លោកបានបញ្ចប់ថ្នាក់អនុបណ្ឌិតផ្នែកច្បាប់។ ពីឆ្នាំ១៩៩៧ ដល់បច្ចុប្បន្ន លោកបានបម្រើការងានៅអង្គការក្រៅរដ្ឋាភិបាលរយៈពេលជាង៨ឆ្នាំ បន្ទាប់មកលោកគឺជាមេធាវីឯកជនជាង៩ឆ្នាំ។



**លោក គីម ធារិទ្ធ**

**ហេរញ្ញិក**

លោក គីម ធារិទ្ធ មានស្រុកកំណើតនៅរាជធានីភ្នំពេញ។ លោកបានបញ្ចប់ថ្នាក់បរិញ្ញាបត្រផ្នែកវិទ្យាសាស្ត្រសេដ្ឋកិច្ច នៅឆ្នាំ២០១៥ និងកំពុងបន្តការសិក្សាថ្នាក់អនុបណ្ឌិត ផ្នែកគ្រប់គ្រងហិរញ្ញវត្ថុបន្ថែមទៀត។ ចាប់ពីឆ្នាំ២០១៤ រហូតដល់ឆ្នាំ២០១៦ លោកបានចូលបម្រើការងារនៅក្រុមហ៊ុន លី ហួរ គ្រុប ក្នុងមុខងារដូចជា ជំនួយការអនុប្រធានគម្រោង និងប្រធានស្តុទីផ្នែកឃ្លាំង។



**កញ្ញា ប៉ូ សុគន្ធា**

**មន្ត្រីរដ្ឋបាល និងលេខា**

កញ្ញា ប៉ូ សុគន្ធា មានស្រុកកំណើតនៅខេត្តតាកែវ។ កញ្ញាបានបញ្ចប់ថ្នាក់បរិញ្ញាបត្រផ្នែកគណនេយ្យ នៅឆ្នាំ២០១២ និងថ្នាក់បរិញ្ញាបត្រផ្នែកអក្សរសាស្ត្រអង់គ្លេស នៅឆ្នាំ២០១៥។ ពីឆ្នាំ២០១២ ដល់ឆ្នាំ២០១៥ កញ្ញាបានបម្រើការងារនៅក្នុងរោងចក្រកាត់ដេរ ដែលមានតួនាទីជាជំនួយការផ្នែករដ្ឋបាល។ ចាប់ពីខែមិថុនា ឆ្នាំ២០១៥ កញ្ញាបានចូលបម្រើការងារនៅក្នុងក្រុមហ៊ុន Millennium Penata Futures ដែលមានតួនាទីជាជំនួយការផ្នែករដ្ឋបាល និងជាជំនួយការអ្នកគ្រប់គ្រងទូទៅ។



**លោក លីម វ៉ាន់ដារ័ត្ន**

**ជំនួយការទីប្រឹក្សាច្បាប់**

លោក លីម វ៉ាន់ដារ័ត្ន មានស្រុកកំណើតនៅខេត្តតាកែវ។ លោកបានបញ្ចប់ថ្នាក់បរិញ្ញាបត្រ ផ្នែកច្បាប់ នៅឆ្នាំ២០១៦។ ដើមឆ្នាំ២០១៣ លោកបានបម្រើការងារនៅរោងចក្រកាត់ដេរសម្លៀកបំពាក់ ផ្នែករដ្ឋបាល។ នៅឆ្នាំ២០១៤ លោកបានបម្រើការងារផ្នែកទេសចរណ៍ជាអ្នកគ្រប់គ្រងទូទៅក្នុងការរៀបចំដំណើរកំសាន្តសម្រាប់ភ្ញៀវទេសចរណ៍ទៅក្រៅប្រទេស។

# សមាជិករបស់សមាគមអ្នកអភិវឌ្ឍន៍លំនៅឋានកម្ពុជា



**លោកឧកញ៉ា លី ហួរ**
**ប្រធានសមាគម**

ប្រធានក្រុមហ៊ុន
ក្រុមហ៊ុន លី ហួរ គ្រុប

OKNHA Ly Hour
President of Ly Hour Group
Tel: 092 668 668
E-mail: hour.ly@lyhourgroup.com



**អ្នកឧកញ៉ា ហុង ពីវ**
**អនុប្រធានសមាគម**

អគ្គនាយក
ក្រុមហ៊ុន ពិភពថ្មី គ្រុប

NEAK OKNHA Hong Piv
General Director of Piphup Thmey Group
Tel: 012 668 888



**លោកឧកញ៉ា ថៃ ជាហួត**
**អនុប្រធានសមាគម**

ប្រធានក្រុមប្រឹក្សាភិបាល
ក្រុមហ៊ុន បុរី ប៉េង ហួត គ្រុប ខូអិលធីឌី

OKNHA Thay Chea Huoth
Chairman of Borey Peng Huoth Group Co., Ltd.
Tel: 017 666 999
E-mail: Cheahuoth.thay@penghuoth.com



**លោកឧកញ៉ា ជាម ឃុនណាត**
**អនុប្រធានសមាគម**

ប្រធានក្រុមប្រឹក្សាភិបាល
ក្រុមហ៊ុន មេគង្គភ្នំពេញ ឌីវីឡុបមេន ខបភើរេសិន ខូអិលធីឌី

OKNHA Cheam Khunnath
Chairman of Mekong Phnom Penh Development Corporation Co., Ltd
Tel: 012 851 688



**លោកឧកញ៉ា លាង ម៉េង**
**អនុប្រធានសមាគម**

ប្រធានក្រុមប្រឹក្សាភិបាល
ក្រុមហ៊ុន ជីប ម៉ុង គ្រុប

OKNHA Leang Meng
Group Chairman of Chip Mong Group
Tel: 095 855 855
E-mail: meng.leang@hqgtrading.com



**លោកឧកញ៉ា តេង ហឿង**
**អនុប្រធានសមាគម**

អគ្គនាយករង
ក្រុមហ៊ុនបុរី អ័រគីដេវីឡា ខូអិលធីឌី

OKNHA Teng Hoeung
Deputy Director of Borey Orkide Villa Co., Ltd.
Tel: 012 698 888
E-mail: hoeung.teng@tenglaygroup.com



**លោកជំទាវ ខា ឡេង**
**អនុប្រធានសមាគម**

អគ្គនាយិការង
ក្រុមហ៊ុន អាល់ហ្វា ប្រផឹធី ខនស្ត្រាក់សិន គ្រុប ខូអិលធីឌី

CHUMTEAV Kha Leng
Deputy Director of Alpha Property Construction Group Co., Ltd
Tel: 012 633 888



**លោកជំទាវឧកញ៉ា កែវ ម៉ាលី**
**អនុប្រធានសមាគម**

អគ្គនាយិកា
ក្រុមហ៊ុន ខុនដូ វិមាន កែវចរណៃ

CHUMTEAV OKNHA Keo Maly
General Director of Keo Choronai Condominium
Tel: 012 814 333



**លោកឧកញ៉ា លី សេងឃាង**
**អនុប្រធានសមាគម**

ប្រធានក្រុមហ៊ុន
ក្រុមហ៊ុន ប៊ីអេស លែន & ហូម ខូអិលធីឌី

OKNHA Ly Seng Kheang
President of BS Land & Home Co., Ltd
Tel: 012 892 829
E-mail: sengkheangly@gmail.com



**លោកឧកញ៉ា លាង សាំង**
**អនុប្រធានសមាគម**

អគ្គនាយក
ក្រុមហ៊ុន អេសអិល ហាយ ធិច ខូអិលធីឌី

OKNHA Leang Saing
General Director of SL Hi-Tech Co., Ltd
Tel: 070 668 888
E-mail: phally88@gmail.com



**លោកឧកញ៉ា តាំង គួង**
**អនុប្រធានសមាគម**

អគ្គនាយក
ក្រុមហ៊ុន តាំង គួង គ្រុប

OKNHA Tang Kung
Chairman of Tang Kung Group Co., Ltd.
Tel: 012 800 991



**លោកឧកញ៉ា ប៊ុន ហៃ**
**សមាជិកសមាគម**

ប្រធានក្រុមហ៊ុន
ក្រុមហ៊ុន បុរី ភ្នំពេញថ្មី ខូអិលធីឌី

OKNHA Bun Hay
President of Borey Phnom Penh Thmey Co., Ltd
Tel: 012 854 789



**លោកឧកញ៉ា ថៃ ឈុនគ្រី**
**សមាជិកសមាគម**

អគ្គនាយក
ក្រុមហ៊ុន ថៃ ឈុនគ្រី អាហារណ៍នីហរណ៍

OKNHA Thai Chhunkry
General Director of Thai Chhunkry Import & Export Co.,Ltd
Tel: 011 880 080
E-mail: boreytck@gmail.com



**លោកឧកញ៉ា ព្រំ សុធី**
**សមាជិកសមាគម**

អគ្គនាយក
ក្រុមហ៊ុន អង្គរ ខនធីណឹន គ្រុប ខូអិលធីឌី

OKNHA Prom Sothy
General Director of Angkor Continent Group Co., Ltd.
Tel: 012 432 888
E-mail: pst@boreyapp.com



**លោកឧកញ៉ា លីម ឈាងហាក់**
**សមាជិកសមាគម**

ប្រធានក្រុមហ៊ុន
ក្រុមហ៊ុន លីម ឈាងហាក់ ខូអិលធីឌី

OKNHA Lim Chheang Hak
President of Lim Chheang Hak Co., Ltd
Tel: 066 277 277



**លោក ចាន់ សុង**
**សមាជិកសមាគម**

ប្រធានក្រុមប្រឹក្សាភិបាល
ក្រុមហ៊ុន ខេមបូឌាន នេជ្រល ឡាក់ឃី រៀលអ៊ីស្ទេត ឌីវេឡុបមេន ខូអិលធីឌី

Mr. Chan Song
Chairman of Board Director of Cambodia Natural Lucky Real Estate Development Co., Ltd. Tel: 088 333 6666





**លោក ទន់ ឆៃលីម**
**សមាជិកសមាគម**

នាយកក្រុមហ៊ុន
ក្រុមហ៊ុន តាំង លីម ខូអិលធីឌី

Mr. Toun Chhay Lim
Director of Tang Lim Co., Ltd
Tel: 012 815 161
E-mail: chhavrathkhy@yahoo.com



**លោក ខូយ អ៊ាងឡាយ**
**សមាជិកសមាគម**

ប្រធានក្រុមហ៊ុន
ក្រុមហ៊ុន បុរី ហុង ឡាយ ខូអិលធីឌី

Mr. Khoy Eang Lay
President of Borey Hong Lay Co., Ltd
Tel: 092 570 999
E-mail: sengts77@gmail.com



**លោក អ៊ីវ ម៉េង**
**សមាជិកសមាគម**

ប្រធានក្រុមហ៊ុន
សំណង់ល្អ ថ្មីពេញចិត្ត

Mr.Iv Meng
President of Laor Thmey Penh Chet Construction
Tel: 012 690 089



**ឯកឧត្តម មាស វណ្ណា**
**សមាជិកសមាគម**

អគ្គនាយក
បុរី ញូវថោន

H.E Meas Vanna
General Director of Borey New Town
Tel: 017 881 168
E-mail: taracyrossky@yahoo.com



**លោកឧកញ៉ា គង់ ប៊ុនហាវ**
**សមាជិកសមាគម**

អគ្គនាយក
ក្រុមហ៊ុន បុរី វីឡាទួលសង្កែ

OKNHA Kong Bunhav
General Director of Borey Villa Toul Sangke
Tel: 011 611 777



**ឯកឧត្តម តុល លន**
**សមាជិកសមាគម**

អគ្គនាយក
បុរី ធូ លន

H.E Tol Lorn
General Director of Borey Thou Lorn
Tel: 012 381 168



**លោក ព្រុំ ខយ**
**សមាជិកសមាគម**

ប្រធានក្រុមហ៊ុន
ផ្ទះល្វែង សូឈីវ ព្រុំខយ

Mr. Prum Khay
President of Sochhiv Prum Khay Construction
Tel: 011 833 778



**លោក ស្រេង ឈាងហោ**
**សមាជិកសមាគម**

ប្រធានក្រុមហ៊ុន
ក្រុមហ៊ុន បុរី លឹម ឈាងហោ ខូអិលធីឌី

Mr. Sreng Chheanghor
President of Borey Lim Chheanghor Co., Ltd.
Tel: 011 989 999
E-mail: try.kimleang@yahoo.com



**លោក កៃ ចាន់**
**សមាជិកសមាគម**

ប្រធានក្រុមហ៊ុន
សំណង់លំនៅឋាន សម្បត្តិមាស

Mr. Kay Chan
President of Sambath Meas Resident
Tel: 012 800 580



**លោក ជា រី**
**សមាជិកសមាគម**

អគ្គនាយក
ក្រុមហ៊ុន បុរី ជារី ខូអិលធីឌី

Mr. Chea Ry
General Director of Borey Chea Ry Co., Ltd.
Tel: 010 883 880
E-mail: boreycheary@gmail.com



**លោកជំទាវ សែម សម្ផស្ស**
**សមាជិកសមាគម**

អគ្គនាយិកា
ក្រុមហ៊ុន បុរី សម្បត្តិ មានហេង ៣

CHUMTEAV Sem Samphas
Managing Director of Borey Sambath Mean Heng 3.
Tel: 071 888 8871
E-mail: vizatong@boreysmh.com



**លោក អាន រ៉ាឌី**
**សមាជិកសមាគម**

អគ្គនាយក
ក្រុមហ៊ុន បុរី មង្គលភ្នំពេញ ខូអិលធីឌី

Mr. Ann Rady
General Director of Borey Mongkul Phnom Penh Co., Ltd.
Tel: 017 770 000
E-mail: rady_ann@yahoo.com



**លោកជំទាវ សេង វារី**
**សមាជិកសមាគម**

ប្រធានក្រុមហ៊ុន
ក្រុមហ៊ុន វារីណា អ៊ីនវេសមេន គ្រុប ខូអិលធីឌី

CHUMTEAV Seng Veary
President of Varina Investment Group Co., Ltd



**លោក ឃៀត ផេង**
**សមាជិកសមាគម**

ប្រធានក្រុមប្រឹក្សាភិបាល
ក្រុមហ៊ុន ហាយលែន ស៊ីធី ខនស្ត្រាក់សិន

Mr. Kheat Pheng
Chairman of Board Director of Highland City Construction.
Tel: 078 898 922
E-mail: info@boreyhighlandcity.com



**លោក សួ សុខថេង**
**សមាជិកសមាគម**

ប្រធានគ្រប់គ្រងទូទៅ
ក្រុមហ៊ុន បុរី រិទ្ធិ ខូអិលធីឌី

Mr. Sour Soktheng
General Manager of Borey Rith Co., Ltd
Tel: 012 345 688
E-mail: soursoktheng@hotmail.com



**លោក ឡៅ តុងហាំង**
**សមាជិកសមាគម**

ប្រធានគ្រប់គ្រងទូទៅ
ក្រុមហ៊ុន បុរី គ្រីស្តាល់ ខូអិលធីឌី

Mr. Lao Tong Hang
General Manager of Borey Crystal Co., Ltd
Tel: 097 626 2627
E-mail: gi2002@camintel.com

# សារពីប្រធានសមាគម



តាងនាមខ្ញុំជាប្រធានសមាគមអ្នកអភិវឌ្ឍន៍លំនៅឋានកម្ពុជា ខ្ញុំមានសេចក្តីសោមនស្សរីករាយ និង មានកិត្តិយសក្នុងការផ្តួចផ្តើមបង្កើតសមាគមអ្នកអភិវឌ្ឍន៍លំនៅឋានកម្ពុជានេះឡើង ដោយមានការចូលរួមគាំទ្រពីសមាជិក-សមាជិកាទាំងអស់របស់សមាគម ក្នុងបំណងដ៏ពិសិដ្ឋដើម្បីជួយការពារផលប្រយោជន៍ស្របច្បាប់របស់សមាជិក-សមាជិកា នៃសមាគមអ្នកអភិវឌ្ឍន៍លំនៅឋាននៅកម្ពុជា និង ដើម្បីរួមចំណែក អភិវឌ្ឍន៍វិស័យសំណង់លំនៅឋាននៅកម្ពុជា ឲ្យស្របតាមកំនើនប្រជាជនរស់នៅសមរម្យថ្លៃថ្នូរ និង ស្របតាមគោលនយោបាយរាជរដ្ឋាភិបាលកម្ពុជា ក្នុងការអភិវឌ្ឍន៍វិស័យលំនៅឋាននៅកម្ពុជា ។

ក្រោមការដឹកនាំដ៏ឈ្លាសវៃប្រកបដោយគតិបណ្ឌិតរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា យើងទទួលស្គាល់ថា កម្ពុជាមាន សន្តិភាព ស្ថេរភាព និងការអភិវឌ្ឍន៍លើគ្រប់វិស័យគួរជាទីមោទនៈបំផុត ។ ជាមួយគ្នា នៅក្នុងចំណោមវិស័យសំខាន់នានាដែលជាឆ្អឹងខ្នងសេដ្ឋកិច្ចនៃប្រទេសកម្ពុជា គឺវិស័យសំណង់បានរីកដុះដាលគួរឱ្យកត់ សម្គាល់ពីមួយថ្ងៃទៅមួយថ្ងៃ ក្នុងនោះ អគារទំនើបៗ បុរីលំនៅឋាន ផ្ទះល្វែង មជ្ឈមណ្ឌលពាណិជ្ជកម្ម អគារការិយាល័យ ផ្សារទំនើប និង សំណង់ដែលមានលក្ខណៈទំនើបៗ បានរីកដុះឡើងជាបន្តបន្ទាប់ ។ គិតត្រឹមដើមឆ្នាំ២០១៦ នៅរាជធានីភ្នំពេញ សំណង់អគារខ្ពស់លើសពី៥ជាន់ គឺមានចំនួនជាង៦០០កន្លែង និង សំណង់បុរីមានចំនួនជាង១១០ទីតាំង ហើយសំណង់ទាំងនេះបានពង្រាយពាសពេញទាំង១២ខណ្ឌនៃរាជធានីភ្នំពេញ ។ មិនថាតែនៅរាជធានីភ្នំពេញសូម្បីតែនៅតាមបណ្តាខេត្តនានា គឺវាលស្រែ ឬដីដែលបោះបង់មិនសូវមានតម្លៃត្រូវបានប្រែក្លាយជាដី មានតម្លៃ ហើយពោរពេញដោយសំណង់បុរី លំនៅឋាន ដែលបាន រីកឡើងជា បន្តបន្ទាប់គួរជាទីមោទនៈ ។

ដោយសារការរីកចម្រើនឥតឈប់ឈរទាំងនេះ ទើបតម្រូវឲ្យសមាគម អ្នកអភិវឌ្ឍន៍លំនៅឋានកម្ពុជា មានវត្តមានឡើង ដើម្បីចូលរួមជាចំណែកក្នុងការអភិវឌ្ឍវិស័យសំណង់នៅក្នុងប្រទេសកម្ពុជាឱ្យកាន់តែប្រសើរឡើង ។ សមាគមអ្នកអភិវឌ្ឍន៍លំនៅឋានកម្ពុជាត្រូវបានអនុញ្ញាតដោយរាជរដ្ឋាភិបាលកម្ពុជា តាមរយៈក្រសួងមហាផ្ទៃឱ្យដំណើរការដោយស្របច្បាប់នៅចុងឆ្នាំ២០១៥ ជាសមាគមអព្យាក្រឹត មិនស្វែងរកប្រាក់ចំណេញ មិនធ្វើនយោបាយ មិនបម្រើឱ្យគណបក្សនយោបាយ ពោលគឺធ្វើការបម្រើផលប្រយោជន៍ស្របច្បាប់ដល់សមាជិក-សមាជិកាទាំងអស់របស់សមាគម ព្រមទាំងរួមចំណែកបម្រើដល់ផលប្រយោជន៍ជាសាធារណៈក្នុងកិច្ចការសង្គមតែប៉ុណ្ណោះ។ ជាមួយគ្នានេះ គោលបំណងនិងបេសកម្មរបស់សមាគមក៏នឹងផ្តល់នូវវេទិកាសម្រាប់ផ្លាស់ប្តូរបទពិសោធន៍គ្នាទៅវិញទៅមករវាងអ្នកអភិវឌ្ឍន៍លំនៅឋាន ជាមួយនឹងអាជ្ញាធរពាក់ព័ន្ធ ផ្សព្វផ្សាយផលិតផលនិងសេវាកម្មរបស់ក្រុមហ៊ុនស្វែងរកដៃគូវិនិយោគ និងបណ្តាក់ទុនក្នុងការធ្វើជំនួញតាមរយៈសមាគម ជួយដោះស្រាយបញ្ហារួម និងបញ្ហាដោយឡែករបស់សមាជិក ព្រមទាំងផ្តល់ការប្រឹក្សាយោបល់លើបញ្ហាហិរញ្ញវត្ថុ ពន្ធដារ ច្បាប់លើវិស័យសំណង់ បុរី និងលំនៅឋាន ។ តួនាទីរួម ចំណែកមួយផ្នែកទៀត គឺសមាគមក៏នឹងចូលរួមចំណែកសហការ ផ្តល់ព័ត៌មានជូនដល់រាជរដ្ឋាភិបាលពាក់ព័ន្ធនឹងការអភិវឌ្ឍន៍នៃវិស័យសំណង់លំនៅឋាននៅកម្ពុជា និង ទប់ស្កាត់រាល់ការវិនិយោគដែលមានភាពមិនច្បាស់លាស់ ឬបង្កភាពចលាចលដល់ទីផ្សារលំនៅឋាននៅកម្ពុជា ។ សកម្មភាពទាំងអស់ គឺក្នុងបំណងជារួមដើម្បីរួមចំណែកអភិវឌ្ឍន៍លំនៅឋាននៅកម្ពុជា ព្រមទាំងចូលរួមចំណែកលើកស្ទួយសេដ្ឋកិច្ចជាតិ និងឧត្តមភាពនៃមាតុភូមិកម្ពុជា ។

ជាថ្មីម្តងទៀត តាងនាមឱ្យប្រធានគណៈកម្មាធិការប្រតិបត្តិនៃ សមាគមអ្នកអភិវឌ្ឍន៍លំនៅឋានកម្ពុជា ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់សមាជិកទាំងអស់ដែលបាន ជឿជាក់ គាំទ្រ និងបានចូលជាសមាជិក-សមាជិកានៃសមាគម ។ ខ្ញុំក៏សូមអរគុណដ៏ស្មោះដល់ដៃគូនានា អាជ្ញាធរពាក់ព័ន្ធ ជាពិសេសរាជរដ្ឋាភិបាលកម្ពុជាដែលបានគាំទ្រ និងអនុញ្ញាតឲ្យសមាគមអ្នកអភិវឌ្ឍន៍លំនៅឋានកម្ពុជាបំពេញបេសកម្មរបស់ខ្លួនដោយស្របច្បាប់នៅកម្ពុជា ។ ខ្ញុំមានជំនឿយ៉ាងមុតមាំថា នាថ្ងៃអនាគត និង ជាបន្តបន្ទាប់ ក្រុមហ៊ុនដែលប្រកបអាជីវកម្មលើវិស័យសំណង់នៅប្រទេសកម្ពុជាកាន់តែច្រើនឡើង នឹងសម្រេចចិត្តចុះឈ្មោះចូលជាសមាជិករបស់ សមាគមអ្នកអភិវឌ្ឍន៍លំនៅឋានកម្ពុជា ដើម្បីរួបរួមទាំង កម្លាំង ស្មារតី និង ធនធានក្នុងបុព្វហេតុអភិវឌ្ឍវិស័យសំណង់ បុរី លំនៅឋាន នៅព្រះរាជាណាចក្រកម្ពុជា ឲ្យបានកាន់តែរីកចម្រើនដូចបណ្តាប្រទេសក្នុងតំបន់ និងសកលលោក ៕

# សំណង់
# សម័យអង្គរ











# សំណង់សម័យបារាំង





# វិស័យសំណង់ដែលគេបោះបង់ចោលក្នុងសម័យខ្មែរក្រហម











# អ្វីដែលអ្នកអភិវឌ្ឍន៍លំនៅឋាននៅកម្ពុជាបានរួមចំណែកគឺការប្រែក្លាយវាលស្រែ និងដីបឹង មកជាទីប្រជុំជន បុរី លំនៅឋាន និង ទីក្រុងរណបថ្មីៗគួរជាទីមោទនៈ !

ព្រះរាជាណាចក្រកម្ពុជា តាំងពីបុរាណកាលមកគឺធ្លាប់មានស្នាដៃដ៏អស្ចារ្យលើស្ថាបត្យកម្ម និង សំណង់ នោះគឺជាសំណង់ស្ថាបត្យកម្មក្នុងសម័យមហានគរដ៏រុងរឿងបំផុតរបស់កម្ពុជា ។ សំណង់ដែលមានតាំងពីសម័យកាលនោះ គឺមិនត្រឹមតែជាការបង្ហាញនូវភាពអស្ចារ្យនៃស្ថាបត្យកម្មរបស់ខ្មែរប៉ុណ្ណោះទេ ប៉ុន្តែវត្ថុអស្ចារ្យទាំងនេះបានក្លាយជា និមិត្តរូប អត្តសញ្ញាណជាតិ និង ជាព្រលឹងរបស់ជាតិកម្ពុជា !

ផ្តើមចេញពីសំណង់ដែលមានលក្ខណៈផ្សារភ្ជាប់រវាង សាសនា អាទិទេព និង មនុស្ស កម្ពុជាក្នុងសម័យអាណានិគមបារាំង គឺស្ថាបត្យករខ្មែរ ដែលប្រកបដោយការច្នៃប្រឌិត បានធ្វើទំនើបកម្មឲ្យមានការវិវត្តន៍ថ្មីនៃស្ថាបត្យកម្មខ្មែរ នោះគឺការបូកបញ្ចូលគ្នារវាងគំនិតច្នៃប្រឌិត តាមរចនាបទខ្មែរ និង បែបអឺរ៉ុប ។ កេរ្តិ៍ដំណែលនៃសំណង់ទាំងនេះមាននៅបណ្តាខេត្តមួយ ចំនួនដូចជាពិសេសនៅខេត្តបាត់ដំបង និង នៅរាជធានីភ្នំពេញដែលជាបេះដូងនៃព្រះរាជាណាចក្រកម្ពុជា ។ សំណង់ទាំងនេះមានតម្លៃក្នុងការរំលឹកយើងអំពីប្រវត្តិសាស្រ្ត កម្ពុជាក្នុងគ្រានោះ !

ក្នុងរបត់ប្រវត្តិសាស្រ្តដ៏អកុសល្យ គឺក្នុងគ្រាមួយដែលមាតុភូមិកម្ពុជាធ្លាក់ក្នុងរបបវាលពិឃាត ប៉ុល ពត សំណង់លំនៅឋាននានាមិនត្រឹមតែ មិនត្រូវបានកសាងឡើង ក៏ប៉ុន្តែសំណង់លំនៅឋានដែលមានស្រាប់មួយចំនួនត្រូវបានរុះរើបំផ្លាញចោល ឬទុកឲ្យនៅទំនេរចោលដោយគ្មានមនុស្សរស់នៅឡើយ ។ ឃើញរូបភាពនៃសំណង់កម្ពុជានាសម័យនោះ បានរំលឹកយើងឲ្យនឹកឃើញពី ភាពសោកសៅរាប់មិនអស់របស់កម្ពុជា !

ទោះបីជាយ៉ាងណាក៏ដោយ ប្រវត្តិសាស្រ្តនេះបានជំរុញឲ្យកម្ពុជាប្តេជ្ញាប្រែក្លាយពីការឈឺចាប់ មកជាការខិតខំប្រឹងប្រែងប្រែក្លាយកម្ពុជា ឲ្យអភិវឌ្ឍលើគ្រប់វិស័យ និងឲ្យបានល្អប្រសើរឡើងវិញ ក្នុងនោះរួមទាំងការខិតខំកសាងលើហេដ្ឋារចនាសម្ព័ន្ធ និងសំណង់លំនៅឋានឲ្យបានល្អប្រសើរឡើងវិញផងដែរ ។

ក្រោមការដឹកនាំប្រកបដោយមគ្គុទេសក៏របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ជីវភាពរបស់ប្រជាជនកម្ពុជា បានវិវត្តន៍ប្រែប្រួលកាន់តែប្រសើរឡើងពីមួយថ្ងៃទៅមួយថ្ងៃ ។ កត្តាសន្តិភាព ស្ថេរភាពនយោបាយ ការបើកចំហលើវិស័យពាណិជ្ជកម្មនិងសេដ្ឋកិច្ច បានផ្តល់ឱកាសដល់វិនិយោគិនទាំងក្នុងស្រុក នៅក្រៅស្រុករួមចំណែកអភិវឌ្ឍន៍កម្ពុជា ក្នុងនោះវិស័យអចលនទ្រព្យ សំណង់ លំនៅឋាន បុរីបានក្លាយជាផ្នែកមួយយ៉ាងសំខាន់ក្នុងការរួមចំណែកលើកកម្ពស់ជីវភាពប្រជាជន រុញកំណើនសេដ្ឋកិច្ចជាតិ និង បានលើកកម្ពស់មុខមាត់កិត្យានុភាពកម្ពុជាចំពោះអន្តរជាតិផងដែរ ។ មិនថានៅទីក្រុងភ្នំពេញ សូម្បីតែនៅតាមបណ្តាខេត្តនានាគឺវាលស្រែ ឬដីដែលបោះបង់មិនសូវមានតម្លៃត្រូវបានប្រែក្លាយជាដីមានតម្លៃហើយពោរពេញដោយ សំណង់បុរី លំនៅឋាន អគារខ្ពស់ៗ ដែលបានរីកឡើងជាបន្តបន្ទាប់គួរជាទីមោទនៈ ។

នៅរាជធានីភ្នំពេញមានសំណង់បុរី ផ្ទះវិឡា ផ្ទះល្វែង ផ្សារទំនើប អគារពាណិជ្ជកម្មខ្ពស់ៗ និងខុនដូទំនើបៗបានរីកឡើងទាំងនៅកណ្តាលទីក្រុង និងនៅជាយក្រុង ដែលនេះឆ្លុះបញ្ចាំងឲ្យឃើញពីការវិវត្តន៍ទៅរកជីវភាពបែបស៊ីវិល័យរបស់ប្រជាជនកម្ពុជា ។ គិតត្រឹមដើមឆ្នាំ២០១៦ នៅរាជធានីភ្នំពេញសំណង់អគារខ្ពស់លើសពី៥ជាន់ គឺមានចំនួនជាង៦០០កន្លែង និង សំណង់បុរីមានចំនួនជាង ១១០ទីតាំង ហើយសំណង់ទាំងនេះបានពង្រាយពាសពេញទាំង១២ខណ្ឌនៃរាជធានីភ្នំពេញ។ កត្តាទាំងនេះជំរុញឲ្យរាជរដ្ឋាភិបាលកម្ពុជាចាប់ផ្តើមគិតពីគម្រោងផែនការអភិវឌ្ឍក្រុងប្រកបដោយប្រសិទ្ធភាពនិងអាចដោះស្រាយបញ្ហាមួយចំនួនដូចជា កកស្ទះចរាចរណ៍ បរិស្ថាន និង សន្តិសុខ ។







ឆ្លើយតបនឹងតម្រូវការនេះ នៅថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៥ រាជរដ្ឋាភិបាលកម្ពុជា បានអនុម័តប្លង់គោលអភិវឌ្ឍន៍រាជធានីភ្នំពេញជាផ្លូវការ ។ ប្លង់គោលនេះ ជាឯកសារយុទ្ធសាស្រ្តគោលរបស់រាជរដ្ឋាភិបាលដែលមានគោលដៅដល់ឆ្នាំ២០៣៥ ក្នុងការគ្រប់គ្រងតម្រង់ទិសការអភិវឌ្ឍន៍សេដ្ឋកិច្ចក្នុងព្រំប្រទល់រដ្ឋបាលរាជធានី និងតំបន់ទីប្រជុំជនពាក់ព័ន្ធទាំងឡាយនៅជាប់ជុំវិញរាជធានីភ្នំពេញ ដើម្បីឆ្លើយតបនឹងកំណើនប្រជាជន និង កំណើននៃការវិនិយោគឯកជន។ នៅប៉ុន្មានឆ្នាំចុងក្រោយនេះ ទំហំការវិនិយោគលើវិស័យសំណង់គិតជាទឹកប្រាក់មានចំនួន ២៥០០លានដុល្លារក្នុង១ឆ្នាំៗ ហើយការវិនិយោគក្នុងវិស័យនេះក៏បន្តកើនឡើងដល់ទៅទឹកប្រាក់ ជាង៣៣០០ ដុល្លារនៅឆ្នាំ២០១៥ ដោយមានអត្រាកំណើនដល់ទៅជាង ៣០% ។ រាជរដ្ឋាភិបាលកម្ពុជាបានផ្តល់ឱកាសនិងយកចិត្តទុកដាក់ចំពោះវិស័យឯកជន ហើយវិនិយោគិនក្នុងស្រុក និងអ្នកវិនិយោគមកពីក្រៅប្រទេស គឺមានឱកាសដូចគ្នា ជាពិសេសធុរជនក្នុងស្រុកបានដើរតួនាទីសំខាន់នៅក្នុងវិស័យអចលនទ្រព្យនៅកម្ពុជា ។

ដោយមើលឃើញពីភាពចាំបាច់ទាំងបច្ចុប្បន្ន និងទៅអនាគត សមាគមអ្នកអភិវឌ្ឍន៍លំនៅឋាននៅកម្ពុជា ដែលបានបង្កើតឡើងនេះ ហើយមានសមាសភាពប្រមូលផ្តុំដោយធុរជនក្នុងស្រុក និង ក្រៅស្រុក គឺមានគោលបំណងដ៏ពិសិដ្ឋ ដើម្បីជួយការពារផលប្រយោជន៍ស្របច្បាប់របស់សមាជិក-សមាជិកា នៃសមាគមអ្នកអភិវឌ្ឍន៍លំនៅឋាន និង ដើម្បីរួមចំណែកដល់ការអភិវឌ្ឍន៍សំណង់លំនៅឋាននៅកម្ពុជាឲ្យស្របនឹងតម្រូវការជាក់ស្តែងរស់នៅសមរម្យថ្លៃថ្នូររបស់ប្រជាជន និង ស្របតាមគោលនយោបាយរាជរដ្ឋាភិបាលកម្ពុជាក្នុងការអភិវឌ្ឍន៍វិស័យលំនៅឋាននៅកម្ពុជា ៕









# ផែនទីរាជធានីភ្នំពេញ








# រដ្ឋាភិបាលកម្ពុជាបានអនុម័តប្លង់គោលរាជធានីភ្នំពេញ ពីបច្ចុប្បន្នរហូតដល់ឆ្នាំ ២០៣៥

រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី បានអនុម័តប្លង់គោលអភិវឌ្ឍន៍រាជធានីភ្នំពេញជាផ្លូវការ នៅ ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៥ ។ ប្លង់គោលនេះត្រូវបានកំណត់លក្ខណវិនិច្ឆ័យចំនួន ១៤ ចំណុច ដើម្បីធ្វើឲ្យប្រសើរឡើងនូវការរៀបចំនគរូបនីយកម្មទីក្រុងភ្នំពេញដែល កំពុងមានកំណើនប្រជាសាស្ត្រ សេដ្ឋកិច្ច និងនគរូបនីយកម្ម ក្នុងនោះរួមមាន៖

១) ទម្រង់សេដ្ឋកិច្ចរាជធានីភ្នំពេញ
២) ការដឹកជញ្ជូន
៣) ទីផ្សារអចលនវត្ថុ
៤) សង្កាត់មិនរៀបរយ
៥) ការកកើតនិងការរីកចម្រើនរបស់ទីក្រុងពីឆ្នាំ១៨៥០ ដល់ឆ្នាំ១៩៩៣
៦) លក្ខណៈសម្បត្តិរូបសាស្ត្រ និងតួនាទីលំហក្រុង
៧) សន្ទុះ និងបុគ្គលិកលក្ខណៈទីក្រុងភ្នំពេញ
៨) ទេសភាព និងសមាសភាគទីក្រុង
៩) កសិកម្មនិងនគរូបនីយកម្ម
១០) ហេដ្ឋារចនាសម្ព័ន្ធទីក្រុង
១១) មធ្យោបាយនិងសេវាសាធារណៈ
១២) និន្នាការនិងទស្សនវិស័យនៃនគរូបនីយកម្មភ្នំពេញ
១៣) ទស្សនវិស័យសេដ្ឋកិច្ចសង្គម និងលំហ។

យោងតាមមាត្រា២ នៃអនុក្រឹត្យលេខ៧៧ អនប.ប្រ.ក ចុះថ្ងៃទី ៧ មិថុនា ឆ្នាំ ២០១២ បានកំណត់ថា ប្លង់គោលប្រើប្រាស់ដីថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ជាផែនការ កំណត់ចក្ខុវិស័យ និងយុទ្ធសាស្ត្ររួមសម្រាប់ការអភិវឌ្ឍន៍ផ្នែករូបវ័ន្ត ហេដ្ឋារចនាសម្ព័ន្ធ និងគមនាគមន៍សំខាន់ៗ និងធ្វើសមាហរណកម្មថ្នាក់រាជធានី ថ្នាក់ស្រុក ថ្នាក់ខណ្ឌ ទៅនឹងតំបន់ និងថ្នាក់ជាតិ។

គោលដៅប្រើប្រាស់ដីរាជធានីភ្នំពេញឆ្នាំ ២០៣៥ ជាឯកសារយុទ្ធសាស្ត្របម្រើ ឲ្យមហិច្ឆតារបស់រាជរដ្ឋាភិបាល ក៏ដូចជាសាលារាជធានីភ្នំពេញ មានគោលដៅ និងទស្សនវិស័យដល់ឆ្នាំ ២០៣៥ ក្នុងការគ្រប់គ្រង និងតម្រង់ទិសការអភិវឌ្ឍន៍ សេដ្ឋកិច្ចក្នុងព្រំប្រទល់រដ្ឋបាលរាជធានី និងតំបន់ប្រជុំជនពាក់ព័ន្ធទាំងឡាយនៅ ជាប់ជុំវិញ ឲ្យឆ្លើយតបបានទៅនឹងកំណើននៃការវិនិយោគឯកជន និងចំនួនប្រជាជន ក្នុងរាជធានីតាមរយៈការតម្រង់ទិស និងជំរុញការវិនិយោគសាធារណៈស្របតាម របបសេដ្ឋកិច្ចទីផ្សារសេរី និងអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ។

តាមការធ្វើអង្កេតប្រជាសាស្ត្រកម្ពុជា ប្រជាជនសរុបនៅរាជធានីភ្នំពេញអាច កើនដល់៣ លាននាក់នៅឆ្នាំ ២០២០ ។ កំណើននគរូបនីយកម្ម និងកំណើនការ សាងសង់សំណង់ធំថ្មីៗលើសពី ៥ ជាន់មានប្រមាណ ៦២៨ អគារ និង សំណង់ បុរីចំនួន ១១០ ទីតាំង ពង្រាយនៅគ្រប់ខណ្ឌ ក្នុងក្រុង និងជាយក្រុង និងបានជំរុញ ការរីកទីក្រុងទៅតំបន់ខាងក្រៅចេញពីខណ្ឌកណ្តាលក្រុង ស្ទើរតែហួសពីតំបន់ រដ្ឋបាលរបស់ក្រុងភ្នំពេញ ។ ទីក្រុងភ្នំពេញបានកំពុងពង្រីកខ្លួន ដែលគេសង្កេត ឃើញមានការប្រែប្រួលជារៀងរាល់ឆ្នាំ អាស្រ័យដោយមានស្ថេរភាពនយោបាយ កំណើនសេដ្ឋកិច្ចកម្ពុជា និងកំណើននៃការអភិវឌ្ឍន៍លើគ្រប់វិស័យរួមទាំងវិស័យ សំណង់ និងលំនៅឋានផងដែរ ។

# រាជរដ្ឋាភិបាលបាននិងកំពុងរៀបចំផែនការយុទ្ធសាស្ត្រ អភិវឌ្ឍរាជធានីភ្នំពេញ ដែលជាបេះដូងកម្ពុជារយៈពេលវែង

ថ្ងៃ សុក្រ ទី ១១ ខែ ធ្នូ ឆ្នាំ ២០១៨ ដោយ : GNN

យោងតាមសេចក្ដីប្រកាសព័ត៌មានរបស់អង្គភាពព័ត៌មាន និងប្រតិកម្មរហ័សនៃទីស្ដីការ គណៈរដ្ឋមន្ត្រី ស្ដីពីលទ្ធផលនៃសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១៥នេះ បានឲ្យដឹងថា ក្រោយពីបាន ស្ដាប់របាយការណ៍ និងមតិពិភាក្សាផ្លាស់ប្ដូរយោបល់រួចមក កិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ដែលប្រព្រឹត្តទៅក្រោមអធិបតីភាព សម្ដេចតេជោ **ហ៊ុន សែន** បានសម្រេចអនុម័ត សេចក្ដីព្រាងអនុក្រឹត្យ ស្ដីពីការដាក់ឱ្យអនុវត្តប្លង់គោលប្រើប្រាស់ដីរាជធានីភ្នំពេញ ដែលក្នុងចក្ខុវិស័យដល់ឆ្នាំ២០៣៥ខាងមុខ រាជធានីភ្នំពេញជាបេះដូងរបស់ប្រទេសកម្ពុជា ជាមជ្ឈមណ្ឌល នយោបាយ សេដ្ឋកិច្ច ពាណិជ្ជកម្ម វប្បធម៌ ប្រកបដោយសក្ដានុពលប្រកួតប្រជែង និងមានការអភិវឌ្ឍនៅទីតាំងភូមិសាស្ត្រពិសេសនៃទន្លេចតុមុខ។

សេចក្ដីប្រកាសព័ត៌មានបញ្ជាក់ថា ប្លង់គោលប្រើប្រាស់ដីរាជធានីភ្នំពេញឆ្នាំ២០៣៥ ជាឯកសារយុទ្ធសាស្ត្រគោល បម្រើឱ្យមហិច្ឆតារបស់រាជរដ្ឋាភិបាល ក៏ដូចជាសាលារាជធានីភ្នំពេញ មានគោលដៅដល់ឆ្នាំ ២០៣៥ ក្នុងការគ្រប់គ្រងតម្រង់ទិសការអភិវឌ្ឍសេដ្ឋកិច្ច ក្នុងព្រំប្រទល់រដ្ឋបាលរាជធានី និងតំបន់ទីប្រជុំជនពាក់ព័ន្ធទាំងឡាយនៅជាប់ជុំវិញ ឆ្លើយតបនឹងកំណើននៃការវិនិយោគឯកជន និងប្រជាជនក្នុងរាជធានី។

ដើម្បីបម្រើគោលដៅខាងលើ ប្លង់គោលនេះនឹងតម្រង់ទិសការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគាំទ្រធំៗ ប្រព័ន្ធផ្លូវ ប្រព័ន្ធទឹកស្អុយ ទឹកស្អាត បឹង កំពង់ផែ ព្រលានយន្តហោះ ឧទ្យាន និងលំហបៃតង ការរៀបចំគោលនយោបាយ លំនៅឋាន ការអភិរក្សបេតិកភណ្ឌទីក្រុង តាមរយៈការការពារបរិស្ថាន និង ការធ្វើតុល្យកម្មនៃការប្រើប្រាស់ធនធានធម្មជាតិ និង បង្កើតឱ្យមានផែនការគ្រប់គ្រងមួយច្បាស់លាស់ នៃធនធានដី ទឹក ថាមពល ប្រព័ន្ធអេកូឡូស៊ី ព្រៃឈើ រ៉ែ ។ល។

នៅក្នុងរបាយការណ៍ដែលបានលើកឡើងក្នុងកិច្ចប្រជុំដ៏សំខាន់នេះ បានគូសបញ្ជាក់ថា រាជធានីភ្នំពេញបានទទួលការអភិវឌ្ឍយ៉ាងលឿនហួសពីការស្មាន ទន្ទឹមនឹងនេះ ទីក្រុងភ្នំពេញក្នុងពេលបច្ចុប្បន្ន ក៏បាននិងកំពុងជួបប្រទះនឹងបញ្ហាប្រឈមថ្មីៗជាច្រើនដូចជា៖ កំណើនប្រជាជនខ្ពស់រហូតដល់២,៣៤% (ប្រហែលជិតមួយម៉ឺនគ្រួសារក្នុងមួយឆ្នាំ) ចំនួនប្រជាជនសរុបនៅភ្នំពេញមានជិត ២លាននាក់ (១.៦៨៨.០៤៤នាក់តាមការធ្វើអង្កេតចន្លោះជំរឿនប្រជាសាស្ត្រកម្ពុជាឆ្នាំ២០១៣ នៃក្រសួងផែនការ) និងមានដង់ស៊ីតេប្រមាណជា២៤៦៨នាក់/គម២ ហើយអាចកើនដល់៣លាននាក់នៅឆ្នាំ២០២០។ ដំណើរនគរូបនីយកម្ម និងកំណើនការសាងសង់សំណង់ធំៗថ្មីៗជាច្រើន (សំណង់អគារខ្ពស់លើសពី៥ជាន់មានប្រមាណ៦២៨កន្លែង និងសំណង់បុរីមានជាង១១០ទីតាំង) ពង្រាយនៅទាំងខណ្ឌក្នុងក្រុង និងជាយក្រុង និងបានជំរុញការរីកទីក្រុង ទៅតំបន់ខាងក្រៅ ចេញពីខណ្ឌកណ្ដាលក្រុងស្ទើរតែហួសពីព្រំប្រទល់រដ្ឋបាលរបស់ខ្លួន។ ជាមួយគ្នានេះ ចំនួនមធ្យោបាយដឹកជញ្ជូន (ចំនួនរថយន្តប្រមាណជា៣៤ម៉ឺនគ្រឿង និងទោចក្រយានយន្តមានជាង១.៧លានគ្រឿង) និងកំពុងបន្តកើនឡើងជារៀងរាល់ថ្ងៃ បង្កការកកស្ទះចរាចរណ៍ និងការបំពុលបរិស្ថានគួរឱ្យកត់សម្គាល់ពីមួយថ្ងៃទៅមួយថ្ងៃ៕

**អត្ថបទ៖ ច័ន្ទ ទេវី**

# រាជធានីភ្នំពេញត្រូវបានពង្រីកធ្វើប្លង់គោលរហូតដល់ឆ្នាំ២០៣៥

(ថ្ងៃ ទី២២ ខែមេសា ឆ្នាំ២០១៥) ដោយៈ មាតាកម្ពុជា

ភ្នំពេញ ៖ របាយការណ៍ពីសាលារាជធានីភ្នំពេញ បានឲ្យដឹងថា រាជធានីគុជមួយនេះបានពង្រីកផ្ទៃដីរហូតដល់ជាង៦៧៨គីឡូម៉ែត្រការ៉េ ស្មើនឹង០,៣៧ភាគរយនៃផ្ទៃដីសរុបទូទាំងប្រទេស។ ប្រជាជនដែលរស់នៅក្នុងរាជធានីភ្នំពេញមាន ប្រមាណជាង១.៥ លាននាក់ ក្នុងអត្រាកំណើនពីមួយឆ្នាំទៅមួយឆ្នាំចំនួន១.៤ ភាគរយនៃចំនួន ប្រជាជន កម្ពុជាសរុប ស្មើនឹងជាង២២ម៉ឺននាក់។ អង្គភាពមួយនេះ បានព្យាករណ៍ថា តម្រូវការផ្ទះសម្បែងសម្រាប់ការរស់នៅរបស់ ពលរដ្ឋអាចប្រហាក់ប្រហែលជាង២០ ម៉ឺន ផ្ទះក្នុងមួយឆ្នាំៗ សម្រាប់ពេលអនាគត។

ផែនការអភិវឌ្ឍន៍រាជធានីភ្នំពេញត្រូវបានពង្រីកប្លង់គោល រហូតដល់ឆ្នាំ២០៣៥ ខណៈបច្ចុប្បន្ន នៅមិនទាន់បានប្រកាសទទួលស្គាល់ជាសាធារណៈនៅឡើយ ។ ប្លង់គោលនេះ ជាការតម្រង់ទិសនៃការអភិវឌ្ឍដោយផ្សារភ្ជាប់ពីទីក្រុងទៅជនបទ ឬហៅថាតំបន់ប៉ូលអភិវឌ្ឍន៍ដោយកំណត់ទៅលើ កម្ពស់សំណង់ គម្លាតសំណង់ តំបន់ហាមមិនឲ្យសាងសង់ទីក្រុងរណបជាដើម។

«សេចក្ដីព្រាងប្លង់គោលសម្រាប់រៀបចំផែនការអភិវឌ្ឍន៍រាជធានីភ្នំពេញ កាលពីដំបូងឡើយ ត្រូវបានកំណត់ត្រឹមតែឆ្នាំ២០២០ប៉ុណ្ណោះ ប៉ុន្តែពេលនេះក្រុមមន្ត្រីជំនាញបានធ្វើបច្ចុប្បន្នភាព ដោយពង្រីកវិសាលភាពរហូតដល់ឆ្នាំ២០៣៥»។ នេះបើតាមការបញ្ជាក់ឲ្យដឹងពី លោក ឡុង ឌីម៉ង់ អ្នកនាំពាក្យសាលារាជធានីភ្នំពេញ។

លោកបានបញ្ជាក់ឲ្យដឹងថា បច្ចុប្បន្នប្លង់គោលនេះមិនទាន់ទទួលបានការអនុម័ត និងឆ្លងកិច្ចប្រជុំគណៈរដ្ឋមន្ត្រីនៅឡើយទេ តែរំពឹងថាប្លង់គោលនេះនឹងត្រូវដាក់ឆ្លងទៅគណៈរដ្ឋមន្ត្រីនៅក្នុង ឆ្នាំ ២០១៥ នេះ ។ បច្ចុប្បន្ននេះ ក្រុមមន្ត្រីជំនាញកំពុង រៀបចំប្រជុំអន្តរក្រសួងមុននឹងបញ្ជូនទៅ ទីស្ដីការគណៈរដ្ឋមន្ត្រីដើម្បីទទួលបានការអនុម័ត។

យ៉ាងណាក៏ដោយ លោក ឡុង ឌីម៉ង់ បានបញ្ជាក់ឲ្យដឹងថា ការរៀបចំប្លង់គោលនេះ មិនមែនជាការត្រៀមពង្រីករាជធានី ភ្នំពេញនោះទេតែការរៀបចំប្លង់គោលនេះ ដើម្បីសិក្សាពីកំណើនប្រជាសាស្ត្រនិងកំណើនសេដ្ឋកិច្ច ដើម្បីងាយស្រួលរៀបចំផែនការគ្រប់គ្រងទីក្រុងឲ្យបានល្អប្រសើរនាពេល អនាគត។ លោកថ្លែងថា «ពីដំបូងការរៀបចំប្លង់ គោលរាជធានីភ្នំពេញ មានការជួយជ្រោមជ្រែងពីក្រុមការងារជំនាញមកពីទីក្រុង ប៉ារីសប្រទេសបារាំង។ ប៉ុន្តែចុងក្រោយ នេះមានការធ្វើបច្ចុប្បន្នភាពចាប់ពីឆ្នាំ ២០២០ ទៅដល់ឆ្នាំ២០៣៥រៀបចំ ដោយក្រុមការងារបច្ចេកទេសរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់សហការ ជាមួយក្រុមមន្ត្រីជំនាញរបស់សាលារាជធានីភ្នំពេញ។

អ្នកនាំពាក្យក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ លោក ម៉េង ប៊ុណ្ណារិទ្ធ បានទទួលស្គាល់ថា ពិតជាមានការពង្រីកវិសាលភាពប្លង់គោល រាជធានីភ្នំពេញ ប្រាកដមែន។ លោកថ្លែងថា «ពិតជាមានការពង្រីកវិសាលភាព ពីឆ្នាំ២០២០ដល់ឆ្នាំ២០៣៥ពិតប្រាកដ មែនដោយបច្ចុប្បន្ន ក្រុមការងារកំពុង រៀបចំបែបបទ និងនីតិវិធីដាក់ឆ្លងគណៈរដ្ឋមន្ត្រី»។

របាយការណ៍របស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានីភ្នំពេញ បានឲ្យដឹងថាផែនការ អភិវឌ្ឍរាជធានីភ្នំពេញ បាននឹងកំពុងកសាងជាប្លង់គោលដោយការកំណត់ចក្ខុវិស័យ និងយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍន៍ជារូបវន្ត និងការកំណត់ប្រភេទដីនៃការប្រើប្រាស់ដី ប្រភេទអាចសាងសង់បាន និងប្រភេទដី កម្រិតសាងសង់ ដោយការកំណត់តំបន់ លំនៅឋាន ពាណិជ្ជកម្ម វប្បធម៌ ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ សេវាសាធារណៈ លំហសាធារណៈ និង ផែនការរូបវន្ត ដែលសំដៅដល់ការធ្វើសមាហរណកម្មផែនការប្រើប្រាស់ដី និង ផែនការហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដើម្បីធានាការអភិវឌ្ឍន៍ ការអភិរក្ស និងការសាងសង់ ក្នុងទីក្រុងឲ្យមានចីរភាព តុល្យភាព សុខុមាលភាព សោភ័ណភាព និងសមធម៌ ។ ប្លង់គោលនេះ ជាការតម្រង់ទិសនៃការអភិវឌ្ឍ ដោយផ្សារភ្ជាប់ពីទីក្រុងទៅជនបទ ឬហៅថាតំបន់ប៉ូលអភិវឌ្ឍន៍ដោយកំណត់ទៅលើកម្ពស់សំណង់គម្លាត សំណង់ តំបន់ហាមមិនឲ្យសាងសង់ ប្លង់ អភិវឌ្ឍន៍តំបន់ខាងជើង ប្លង់ប្រព័ន្ធផ្លូវនៃសង្កាត់បឹងទំពុន ប្លង់ប្រព័ន្ធផ្លូវនៃសង្កាត់ព្រែកប្រា ប្លង់អភិវឌ្ឍន៍នៃត្រើយខាងកើតទន្លេជាដើម៕

## កិច្ចប្រជុំផ្ទៃរបស់សមាគមអ្នកអភិវឌ្ឍន៍លំនៅឋានកម្ពុជា
## នៅថ្ងៃទី០៨ ខែមិនា ឆ្នាំ២០១៦







## "សន្និបាតវិសាមញ្ញរបស់សមាគមអ្នកអភិវឌ្ឍន៍លំនៅឋានកម្ពុជា
## នៅថ្ងៃទី២៥ ខែមិនា ឆ្នាំ២០១៦"










# ការិយាល័យរបស់សមាគម












## កិច្ចប្រជុំជាមួយអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៦










## កិច្ចប្រជុំជាមួយអគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៦










# ការអភិវឌ្ឍន៍រាជធានីភ្នំពេញ ទៅទិសខាងជើង

## បុរី
## វិមានភ្នំពេញ

បុរី វិមានភ្នំពេញ
លំនៅឋាននៃសុភមង្គល















# បុរី
# ប៉េងហួត





















BTS

# បុរី
# វីឡាទួលសង្កែ













# សំណង់ល្អ ថ្មីពេញចិត្ត










សមាគមអ្នកអភិវឌ្ឍន៍លំនៅឋានកម្ពុជា

# បុរី
# មង្គលភ្នំពេញ





















# បុរីអង្គរភ្នំពេញ






ភូមិគ្រឹះ
មហាវិថីអង្គរ សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ
016 321 888
012 432 888
011 273 888


016 321 888
012 432 888
011 273 888


ផ្ទះល្វែង
មហាវិថីអង្គរ សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ
www.boreyapp.com
011 273 888

# បុរី ថៃ ឈុនគ្រី



ផ្ទះល្វែងហាង | SHOPEHOUSE
ត្រឹមតែ
$145,500
SHOP
SHOP
SHOP
#99 ផ្លូវ សម្តេចជាស៊ីម ភូមិ ត្រពាំងស្វាយ សង្កាត់ ភ្នំពេញថ្មី ខណ្ឌ សែនសុខ រាជធានី ភ្នំពេញ។
Tel: 015 333 456 | 099 980 080




វីឡាកូនកាត់ធំ | Town Villa
ចេញលក់ឆាប់ៗនេះ!
#99 ផ្លូវ សម្តេចជាស៊ីម ភូមិ ត្រពាំងស្វាយ សង្កាត់ ភ្នំពេញថ្មី ខណ្ឌ សែនសុខ រាជធានី ភ្នំពេញ។ Tel: 015 333 456 | 099 980 080








# បុរី តាំង លីម

BOREY TANG LIM
បុរី តាំង លីម



















# ការអភិវឌ្ឍន៍រាជធានីភ្នំពេញ ទៅទិសខាងជើងឆៀងខាងលិច

CHIP MONG
LAND

## បុរី
## ឈីបម៉ុងឡែន











## បុរី
## មេគង្គ រ៉ូយ៉ាល់








ផ្ទះល្វែងអាជីវកម្ម
D&G
DKNY
CHANEL
GUESS
SONY




ZARA
TOM FORD



បុរី វារីណា

BOREY VARINA

បុរី វារីណា














# បុរី ហុង ឡាយ

បុរី ហុង ឡាយ BOREY HONG LAY











# បុរី ឡាយ គង់


LKIG
ឡាយ គង់ អ៊ីនធើណេសិនណល គ្រុប
LAY KUNG INTERNATIONAL GROUP
Crystalline Design






LAY KUNG INTERNATIONAL GROUP Co.Ltd











# បុរី
# លឹម ឈាងហាក់





















## បុរី លឹម ឈាងហោ ចំការដូង
BOREY LIM CHHEANG HOR










# សំណង់ផ្ទះល្វែង
# សូឈីរ ព្រំខយ

























ប៊ុរី
ធូលន











## បុរី ពិភពថ្មី











# បុរី
# អ័រគីដេ វីឡា

ORKIDĒ
VILLA
























សមាគមអ្នកអភិវឌ្ឍន៍លំនៅឋានកម្ពុជា

# ទីក្រុងរណប ហ្គ្រេនភ្នំពេញ

Y.L.P. GROUP CIPUTRA

GRAND PHNOM PENH
INTERNATIONAL CITY












វីឡា ម៉ូណាកូ
Monaco
7 X 20





បុរី ភ្នំពេញថ្មី
BOREY PHNOM PENH THMEY

# បុរីភ្នំពេញថ្មី














## អាល់ហ្វា ប្រជីធី ខនស្រ្តាក់សិន








ខេមបូឌាន នេដ្រល ឡាក់ឃី
រៀលអ៊ីស្តេត ឌីវេឡុបមេន ខូអិលធីឌី
SINO PLAZA
天琪·中國中心






SINO PLAZA
天琪·中國中心


SINO PLAZA
天琪·中國中心

RC BOREY ROUM CHEK បុរី រំចេក

## បុរីរំចេក

















# បុរី ផារី

REAL ESTATE











## បុរី ជ័យឧត្តម














សមាគមអ្នកអភិវឌ្ឍន៍លំនៅឋានកម្ពុជា

# បុរី គ្រីស្តាល់

បុរី. គ្រីស្តាល់
BOREY CRYSTAL







# ខុនដូ ឌី រីវើ

THE RIVER
PREMIUM DEVELOPMENTS











# បុរី ហេងមានជ័យ













# បុរី ហាយធិច














# ខុនដូ វិមានកែវចរណៃ

KEO CHORONAI

GARDEN APARTMENTS















សមាគមអ្នកអភិវឌ្ឍន៍លំនៅឋានកម្ពុជា

# បុរី
# ហាយលែន ស៊ីធី
# ខនស្ត្រាក់សិន
















# បុរី ផុនស៊ុយ










បុរី ពេជ្រ

BOREY PICH









# បុរី រិទ្ធ

















# បុរី សម្បត្តិមានហេង

SMH
BOREY SAMBATH MEANHENG



























# បុរី សម្បត្តិមាស

SM

SAMBATH MEAS












សមាគមអ្នកអភិវឌ្ឍន៍លំនៅឋានកម្ពុជា

# បុរី ឌឹ ផ្លរ៉ា

THE FLORA
ប្រណិតភាពក្នុងការរស់នៅ

















# ខុនដូ ដេ ខេសសល រ៉ូយ៉ាល់

DE CASTLE
Royal











# កម្ពុ បុរី

KPB
kampu borey





























សមាគមអ្នកអភិវឌ្ឍន៍លំនៅឋានកម្ពុជា

North Park
Condominium




































# លំនៅឋាន
# អិល កម្ពុជាភ្នំពេញ

CAMBODIA PHNOM PENH
RESIDENCE















# បុរី រីវើថោន


បុរី រីវើថោន
BOREY RIVER TOWN






















BOREY RIVER TOWN




បុរី រីវើថោន
BOREY RIVER TOWN

# បុរី ចតុមុខ ស៊ីធី

Borey
Chaktomuk City












The
BRIDGE






Artist's Impression



Artist's Impression








សមាគមអ្នកអភិវឌ្ឍន៍លំនៅឋានកម្ពុជា

**THE PREMIER ANGKOR PALACE**

Reflections of status and taste aspiring to city living











| ល.រ | ក្រុមហ៊ុន | ក្រុមហ៊ុន(អង់គ្លេស) |
|---|---|---|
| 01 | លី ហួរ គ្រុប | Ly Hour Group |
| 02 | ពិភពថ្មី គ្រុប | Piphub Thmey Group |
| 03 | បុរី ប៉េង ហួត គ្រុប | Peng Huoth Group Co.,Ltd |
| 04 | ជីប ម៉ុង គ្រុប | Chip Mong Group |
| 05 | មេគង្គភ្នំពេញ ឌីវីឡុបមេន ខបភើរេសិន ខូអិលធីឌី | Meb ng Phnom Penh Dee loment Corporation Co.,Ltd |
| 06 | បុរី អរគីដេវីឡា ខូអិលធីឌី | Borey Ork de Villa Co.,Ltd |
| 07 | អាល់ហ្វា ប្រផឹធី ខនស្រ្តាក់សិន គ្រុប ខូអិលធីឌី | Alpha Property Cons ruc ion Group Co.,Ltd |
| 08 | ខុនដូ វិមានកែវចរណៃ | Keo Choronai Condominium |
| 09 | ប៊ីអេស លែន & ហូម ខូអិលធីឌី | BS Land & Home Co.,Ltd |
| 10 | អេសអិល ហាយ ធិច ខូអិលធីឌី | SL Hi-Teb Co.,Ltd |
| 11 | តាំង គួង គ្រុប ខូអិលធីឌី | Tang Kung Group Co.,Ltd |
| 12 | បុរី ភ្នំពេញថ្មី ខូអិលធីឌី | Borey Phnom Penh Thmey Co.,Ltd |
| 13 | អង្គរ ខនធីណឹន គ្រុប ខូអិលធីឌី | Angb r Continent Group Co.,Ltd |
| 14 | តាំង លីម ខូអិលធីឌី | Tang Lim Co.,Ltd |
| 15 | សំណង់ល្អ ថ្មីពេញចិត្ត | Laor Thmey Penh Chet Cons ruc ion |
| 16 | បុរី ញូវ ថោន | Borey New Town |
| 17 | បុរី វីឡាទួលសង្កែ | Borey Villa Toul Sangk |
| 18 | បុរី ធូ លន | Borey Thou Lorn |
| 19 | ផ្ទះល្វែង សូឈីវ ព្រំខយ | Sob hiv Prum Khay Cons ruc ion |
| 20 | លំនៅឋាន សម្បត្តិមាស | Sambath Meas Res dent |
| 21 | បុរី ជារី ខូអិលធីឌី | Borey Chea Ry Co.,Ltd |
| 22 | លីម ឈាងហាក់ ខូអិលធីឌី | Lim Chheang Hak Co.,Ltd |
| 23 | បុរី ហុងឡាយ ខូអិលធីឌី | Borey Hong Lay Co.,Ltd |
| 24 | បុរី មង្គលភ្នំពេញ ខូអិលធីឌី | Borey Mongk l Phnom Penh Co.,Ltd |
| 25 | បុរី សម្បត្តិ មានហេង ៣ | Borey Sambath Meanheng 3 |
| 26 | បុរី រិទ្ធិ ខូអិលធីឌី | Borey Rith Co.,Ltd |
| 27 | បុរី លឹម ឈាងហោ ខូអិលធីឌី | Borey Lim Chheanghor Co.,Ltd |
| 28 | វារីណា អ៊ីនវេសមេន គ្រុប ខូអិលធីឌី | Varina Inv s ment Group Co.,Ltd |
| 29 | ថៃ ឈុនគ្រី អាហរណ៍នីហរណ៍ | Thai Chhunk y Import & Ex ort Co.,Ltd |
| 30 | ខេមបូឌាន នេជ្រល ឡាក់ឃី រៀលអ៊ីស្ទេត ឌីវីឡុបមេន ខូអិលធីឌី | Cambodian Natural Luk Real Es ate Dev lopment Co.,Ltd |
| 31 | បុរី ហាយលែន ស៊ីធីខនស្រ្តាក់សិន | Highland City Cons ruc ion |
| 32 | បុរី គ្រីស្តាល់ ខូអិលធីឌី | Borey Crys al Co.,Ltd |

The Mekong Royal
Your Pride, Your Luxury, Your Home

បុរី វារីណា
BOREY VARINA

LAY KUNG INTERNATIONAL GROUP

THOU LORN CONSTRUCTION

NW

ORKIDĒ
VILLA

Y.L.P. GROUP
CIPUTRA
GRAND PHNOM PENH
INTERNATIONAL CITY

បុរី ភ្នំពេញថ្មី
BOREY PHNOM PENH THMEY

BOREY PENG HUOTH

CONSTRUCTION

SINO PLAZA
天琪·中國中心

RC BOREY ROUM CHEK

REAL ESTATE

BOREY CRYSTAL

Borey Hi-tech

HIGHLAND
CITY CONSTRUCTION

BOREY PICH

BOREY RITH

SMH
BOREY SAMBATH MEANHENG

SM
SAMBATH MEAS

THE FLORA
ប្រណិតភាពក្នុងការរស់នៅ

DE CASTLE
Royal

សំណង់ល្អ ថ្មីពេញចិត្ត

國際全球地產
International Global Real Estate Co., Ltd.

KPB
kampu borey

North Park
Condominium

L
CAMBODIA PHNOM PENH
RESIDENCE

បុរី រីវើថោន
BOREY RIVER TOWN

The BRIDGE

THE PREMIER ANGKOR PALACE
Reflections of status and taste aspiring to city living

សំណង់ផ្ទះល្វែង
សួឈីវ ព្រំខយ

Borey Chaktomuk City

KEO CHORONAI
GARDEN APARTMENTS

THE RIVER
PREMIUM DEVELOPMENTS

បុរី ហុង ឡាយ BOREY HONG LAY

LCH

TL
BOREY TANG LIM
បុរី តាំង លីម